ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ......៥៧៣៤.....អពដ

L202212280265TD3418

ថ្ងៃ ព្រ.ហ ១១ កើត ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
# ស្តីពី
# ការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ សម្រាប់ឆ្នាំជាប់ពន្ធ ២០២២

អនុលោមតាមមាត្រា ៥ថ្មី និងមាត្រា ២៩ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនដំណឹងដល់លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ជ្រាបអំពីកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ២០២២ ដូចខាងក្រោម៖

១. សហគ្រាសត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមប្រព័ន្ធអនឡាញ (Tax on Income-ToI E-Filing) តាមរយៈតំណភ្ជាប់ www.tax.gov.kh/km/e-service ដោយអនុវត្តស្របតាមសេចក្តីណែនាំលេខ ៣១៤០ អពដ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ដោយត្រូវដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣។

២. សហគ្រាសដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំយ៉ាងយឺតបំផុតក្នុងរយៈពេល ៣ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធ។

៣. សហគ្រាសដែលមានសាខា ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដែលបានមកពីលទ្ធផលសរុបរួមបញ្ចូលគ្នារបស់គ្រឹះស្ថានជាគោលដើម និងគ្រប់សាខាទាំងអស់។ សហគ្រាស ត្រូវប្រកាសនូវបញ្ជីឈ្មោះនៃគណនីចំណូលនិងចំណាយ និងតារាងទ្រព្យសកម្មរយៈពេលវែងរបស់សាខានីមួយៗ ដោយវាយបញ្ចូលទៅក្នុងប្រព័ន្ធត្រង់ផ្នែក "**សាខាសហគ្រាសក្នុងស្រុក**" ។

៤. ចំពោះបុគ្គលិក ឬភ្នាក់ងារសេវាកម្មពន្ធដារ ដែលទទួលបន្ទុកការងារដាក់លិខិតប្រកាសពន្ធប្រចាំខែ ប្រចាំឆ្នាំ ជំនួសមុខឱ្យអ្នកជាប់ពន្ធ ត្រូវធ្វើការភ្ជាប់(Upload) ចូលទៅក្នុងប្រព័ន្ធនូវប័ណ្ណសម្គាល់ខ្លួនបុគ្គលិកករណីជាបុគ្គលិកក្រុមហ៊ុន ឬលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធករណីជាភ្នាក់ងារសេវាកម្មពន្ធដារ។

៥. គ្រប់សហគ្រាសទាំងអស់ ដែលមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំត្រូវភ្ជាប់(Upload)ចូលទៅក្នុងប្រព័ន្ធនូវតារាងតុល្យការ គណនីលទ្ធផល និងព័ត៌មានបន្ថែម (ប្រសិនបើមាន)។

L202212280265TD3418

ក្នុងករណីលោក-លោកស្រី មានសំណួរឬចម្ងល់ផ្សេងៗ សូមទាក់ទងជាមួយការិយាល័យសេវាអ្នកជាប់ពន្ធនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងសាខាពន្ធដារខេត្ត-ខណ្ឌដែលទាក់ទិន ឬអាចទូរស័ព្ទមក Call Center 1277 ឬចូលជជែកសួរក្នុង GDT Live Chat ដែលអាចទាញយកកម្មវិធីទូរស័ព្ទដៃចេញពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមនិងជឿជាក់ថា លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករ របស់សហគ្រាសពិតជាយកចិត្តទុកដាក់ក្នុងការដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណូលតាមច្បាប់កំណត់។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

Grant Thornton (Cambodia) Limited
Unofficial translation

**KINGDOM OF CAMBODIA**
**NATION RELIGION KING**

**MINISTRY OF ECONOMY AND FINANCE**
**GENERAL DEPARTMENT OF TAXATION**
No. 5735 GDT

Phnom Penh, 16 February 2023

NOTIFICATION
ON
THE SUBMISSION OF ANNUAL TAX ON INCOME FOR TAX YEAR 2022

Pursuant to article 5 new and article 29 new of the Law on Taxation promulgated by the Royal Kram no. NS/RKM/0297/03 dated 24 February 1997, the General Department of Taxation is honor to inform directors, managers, or owners of enterprises under self-assessment regime the obligation to submit and pay annual tax on income for year 2022 as follows: -

1. Enterprises shall submit annual tax on income via online system (Tax on Income-ToI E-Filing) through link www.tax.gov.kh/km/e-service by implementing according to Notification no. 3140 GDT dated 18 February 2021 by submitting tax returns and pay tax at latest by 31 March 2023.
2. Enterprises allowed to use different tax year from calendar year shall submit and pay annual tax on income at latest within 3 months after the end of tax year.
3. Enterprises that have branches shall submit annual tax on income from consolidated result derived from principal establishment and all branches. Enterprises shall declare the list of revenue and expense account and non-current assets listing of each branch by inputting onto "local branch" section.
4. For employees or tax agent in charge of submitting monthly/annual tax on behalf of taxpayers shall upload onto the system with employment ID card in case of being employee of the Company or authorized letter from taxpayers in case of being a tax agent.
5. All enterprises are obliged to submit tax returns and pay annual tax on income by upload onto the system with balance sheet, profit and loss statements and additional information (if any).

Should there be any doubts or inquiries, please contact the Taxpayer Service Bureau of the Department of Large Taxpayers, tax branches or call hotline 1277 as well as GDT live chat downloadable from App Store for iOS or Play Store for Android.

The General Department of Taxation strongly hopes and believes that directors, managers, or owners of all enterprises will pay full attention in the fulfillment of their obligations in the submission of annual tax on income and pay tax according to the laws and regulations.

MINISTER ATTACHED TO THE PRIME MINISTER
DELEGATE OF THE ROYAL GOVERNMENT IN CHARGE AS
DIRECTOR GENERAL OF THE GENERAL DEPARTMENT OF TAXATION
SIGNED AND SEALED

**Kong Vibol**